NATIONAL INSTITUTE OF EDUCATION (NIE)

United Nations
Educational, Scientific and
Cultural Organization
국제연합
교육과학문화기구

Asia-Pacific Centre of
Education for International Understanding
under the auspices of UNESCO
유네스코 아시아태평양 국제이해교육원

# ការបញ្ចូលខ្លឹមសារការអប់រំភាពជាពលរដ្ឋសកល ក្នុងកិច្ចតែងការបង្រៀន

---

**GCC in Cambodia**

**August 01, 2024**

---

រៀបចំដោយ គ្រូឧទ្ទេសនៃមជ្ឈមណ្ឌលការអប់រំភាពជាពលរដ្ឋសកលនៅកម្ពុជា
សិក្ខាសាលាសម្រាប់គរុនិស្សិតភាសាបារាំងនៃវិទ្យាស្ថានជាតិអប់រំ



# តើអ្វីជាការអប់រំភាពជាពលរដ្ឋសកល ?

❖ **What is GCED? តើអ្វីជាការអប់រំភាពជាពលរដ្ឋសកល ?**

ការអប់រំភាពជាពលរដ្ឋសកល ជាវិធីសាស្ត្រមួយរបស់អង្គការ UNESCO ដើម្បីជម្នះឧបសគ្គ និងបញ្ហាប្រឈមនានា នៅលើផ្លូវឆ្ពោះទៅរកសន្តិភាព ( Peace ) និងនិរន្តរភាព ( Sustainable ) ពិភពលោក។

❖ **បញ្ញត្តិគោលនៃការអប់រំភាពជាពលរដ្ឋសកល**

**ពុទ្ធិ ( Cognitive ):**

ដើម្បីទទួលបានចំណេះដឹង ការយល់ដឹង និងការត្រិះរិះពិចារណាអំពីបញ្ហាសកល តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការផ្សារភ្ជាប់គ្នាទៅវិញទៅមក និងភាពអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេស និងប្រជាជនផ្សេងៗគ្នា។

**ចិត្ត-សង្គម ( Socio-emotional ):**

ដើម្បីឱ្យមានអារម្មណ៍នៃភាពជាកម្មសិទ្ធិរបស់មនុស្សទូទៅ តម្លៃរួម និងទំនួលខុសត្រូវ ការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ។

**ឥរិយាបថ ( Behavioural ):**

ដើម្បីធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងពិភពលោក ដើម្បីពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព។

Source: Global Citizenship Education: Topics and Learning Objectives (UNESCO, 2015)

# តើខ្លឹមសារការអប់រំភាពជាពលរដ្ឋសកលមានចំណុចគោលអ្វីខ្លះ?

ប្រធានបទទី១៖ ប្រព័ន្ធ និងរចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន ជាតិ និងសកល

ប្រធានបទទី២៖ បញ្ហាដែលប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងរបស់សហគមន៍នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ

ប្រធានបទទី៣៖ ប្រព័ន្ធអំណាចនៃការគ្រប់គ្រងរដ្ឋ

ប្រធានបទទី៤៖ កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្មបុគ្គល

ប្រធានបទទី៥៖ សហគមន៍មនុស្ស និងទំនាក់ទំនងរវាងសហគមន៍ទាំងនោះ

ប្រធានបទទី៦៖ ការគោរពចំពោះភាពចម្រុះ និងភាពខុសគ្នា

ប្រធានបទទី៧៖ សកម្មភាពដែលធ្វើដោយបុគ្គល និងសមូហភាព

ប្រធានបទទី៨៖ ឥរិយាបថទទួលខុសត្រូវប្រកបដោយសីលធម៌

ប្រធានបទទី៩៖ ការចូលរួមសកម្មភាពនានារបស់សង្គម

## សន្តិភាព

## និរន្តរភាព

និរន្តភាពបរិស្ថាន

និរន្តភាពសេដ្ឋកិច្ច

យុត្តិធម៌សង្គម



# តើបញ្ញត្តគោលនៃការអប់រំភាពសកលមានអ្វីខ្លះ?

## ពុទ្ធិ (Cognitive):

ដើម្បីទទួលបានចំណេះដឹង ការយល់ដឹង និងការត្រិះរិះពិចារណាអំពីបញ្ហាសកល តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការផ្សារភ្ជាប់គ្នាទៅវិញទៅមក និងភាពអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេស និងប្រជាជនផ្សេងៗគ្នា។

## ចិត្ត-សង្គម( Socio-emotional ):

ដើម្បីឱ្យមានអារម្មណ៍នៃភាពជាកម្មសិទ្ធិរបស់មនុស្សទូទៅ តម្លៃរួម និងទំនួលខុសត្រូវ ការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ។

## ឥរិយាបថ (Behavioural ):

ដើម្បីធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងពិភពលោក ដើម្បីពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព។



# តើយើងត្រូវបញ្ចូលខ្លឹមសារការអប់រំភាពជាពលរដ្ឋសកលក្នុងកិច្ចតែងការបង្រៀនយ៉ាងដូចម្ដេច?

**១. អាចបញ្ចូលបាននៅគ្រប់ជំហាននៃកិច្ចតែងការបង្រៀន**
**២. អាចបញ្ចូលទៅតាមខ្លឹមសារមេរៀន ដោយគ្រាន់តែបន្ថែមនូវខ្លឹមសារនៃការអប់រំភាពជាពលរដ្ឋសកលដែលនាំឲ្យសិស្សប្តូរឥរិយាបថជាវិជ្ជមាន**
**៣. អាចបញ្ចូលខ្លឹមសារការអប់រំភាពជាពលរដ្ឋសកលទាក់ទងនឹងព្រឹត្តការថ្មីៗ បន្ថែមលើកខ្លឹមសារមេរៀនដែលនាំឲ្យសិស្សប្តូរឥរិយាបថជាវិជ្ជមាន**

ក្នុងកិច្ចតែងការសូមសរសេរ "បញ្ជ្រាប GCED" វត្ថុបំណងនៃការបញ្ជ្រាប ខ្លឹមសារ ឬសកម្មភាពបញ្ជ្រាប និងបញ្ជាក់ពីទំនាក់ទំនងនៃខ្លឹមសារបញ្ជ្រាបនឹងប្រធានបទណាមួយក្នុងប្រធានបទទាំង៩ ត្រង់កន្លែងដែលត្រូវបញ្ជ្រាប GCED។

ឧទាហរណ៍៖ បញ្ជ្រាប GCED ដើម្បីឲ្យសិស្សយល់ដឹងពីការរស់នៅចំរុះជាតិសាសន៍ លុបបំបាត់ការរើសអើងសាសនា។ សកម្មភាព៖ គ្រូនិទានរឿងពីគូស្នេហ៍មួយគូរវាងបុរសជនជាតិខ្មែរ និងនារីខ្មែរអ៊ីស្លាម (ដាក់សាច់រឿងចូល)។ ខ្លឹមសារទាក់ទងនឹងប្រធានបទទី២ និងទី៦។



# សកម្មភាពក្រុមតាមសាលាគរុកោសល្យ

១. សាលាគរុកោសល្យនីមួយៗ ត្រូវរៀបចំកិច្ចតែងការបង្រៀនមួយដែលបញ្ចូលខ្លឹមសារ ការអប់រំភាពជាពលរដ្ឋសកល

២. បទបង្ហាញតាមក្រុមត្រូវធ្វើនៅថ្ងៃបន្ទាប់

